# កាព្យច្បាប់ ប្រុស ឧត្តមស្វាមី

ថាប្រុសឯណា នឹងមានភរិយា លោកឱ្យចេះក្តី ទាំងប្រាំចំពោះ សង្គ្រោះចិត្តស្រី ប្រពន្ធប្រក្រតី ដូចធមិសម្តែង ។

បើប្តីឯណា ពុំកាន់កិរិយា ទាំងប្រាំនេះឯង ហៅប្តីទុជិន ជួលន់ក្រៃលែង ចេះតែកំហែង ចិត្តប្រពន្ធពិត ។

បើប្តីកាន់ច្បាប់ ទាំងប្រាំនេះខ្ជាប់ ហៅប្តីសុចរិត បម្រុងភរិយា ដោយនាក្រមក្រិត្យ ប្រសើរពេកពិត ឥតអ្វីផ្ទឹមឡើយ ។

អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ កុំមានកន្តើយ មានប្រពន្ធហើយ ជាសុខសម្រាន្ត ។

មួយគឺហៅប្តី  ឱ្យប្រើសំដី នឹងប្រពន្ធមាន ពាក្យទន់ពីរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន តាមស័ព្ទវាចា ។

មួយគឺប្រពន្ធ ខុសឆ្គងស្រាលធ្ងន់ កំជេរផ្តាសា ទាត់ធាក់ដៀលដំ ដូចខ្ញុំអាត្មា កុំស្តីដើមថា ឱ្យព្ធសាយស័ព្ទ ។

មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្តាប់ ទាំងគ្រឿងអាហារ ជាការស្រីផ្តាប់ រៀបចំសម្រាប់ ថែទាំរក្សា ។

មួយគឺកុំផ្ទង់ កុំខំបង្កើត តែកូនហើយថា ប្រពន្ធសុខចិត្ត ឱ្យគិតប្រាថ្នា រួសរកទ្រព្យា សម្រាប់ឱ្យផង ។

មួយគឺឱ្យចាប់ ស្រឡាញ់ឱ្យខ្ជាប់ កុំជិនណាយហោង កុំមានប្រពន្ធ ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង ឱ្យស្មើមុខឡើយ ។

សម្តែងសេចក្តី គ្រប់ប្រាំវិថី ចែងចប់ស្រេចហើយ ឱ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្ទង់កុំកន្តើយ ចោលច្បាប់បុរាណ ។

បើប្រុសឯណា ពុំផ្ទង់ចិន្តា ដូចធមិទូន្មាន នៅនឹងភរិយា គ្មានជាសុខសាន្ត ហីនហោចធនធាន ទាស់ទែងលែងគ្នា ។

ឯវិស័យចិត្ត អស់ស្រីផងពិត មានប្តីប្រាថ្នា អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា នៅនាលោកិយ ។

បើខ្វះអំពើ ណាមួយហើយតើ ប្រពន្ធថាប្តី ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី តូចចិត្តស្វាមី អាក់អន់ពុំស្មោះ ។

នេះជាច្បាប់ប្រដៅមនុស្សប្រុស ដែលខ្ញុំបាទ សុខ ផុន បានសិក្សាតាំងពីខ្ញុំបាទនៅវ័យជាកុមារភាព មិនមានចម្លងតាមសៀវភៅណាឡើយ ក្នុងបច្ចុប្បន្ន បើឃើញត្រង់កន្លែងណាដែលខុសសូមលោកជួយកែសម្រួលផង សូមអរគុណ ទុកជាមុន សរសេរនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២

វាយចម្លងដាក់គេហទំព័រវត្ត កាព្យច្បប់ ប្រុសឧត្តមស្វាមី ដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១២